## សំរេច

**មាត្រា ១ :** ផ្តល់ឥណទានបន្ថែមដោយផ្ទេរពីជំពូក ៤១ ‹‹ ចំណាយមិនបានគ្រោងទុក ›› នៃថវិការដ្ឋជូនទៅទីស្តីការគណៈរដ្ឋមន្ត្រីផ្នែកទី ១ ជំពូក ៥០ ‹‹ ឥណទានសាងសង់ ›› ចំនួន ៦២០.៦២០.០០០ រៀល

**មាត្រា ២ :** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១ — នាយករដ្ឋមន្ត្រីទី ២

ព្រះហស្តលេខា និងត្រា — ហត្ថលេខា និងត្រា

**នរោត្តម រណឫទ្ធិ** — **ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ០៩ ខែឧសភា ឆ្នាំ ១៩៩៤

# អនុក្រឹត្យលេខ ២២ អនក្រ ស្តីពីការបង្កើត គណៈបញ្ជាការ ឯកភាពខេត្ត ក្រុង ស្រុក ខណ្ឌ

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេច **ព្រះនរោត្តម សីហនុ វរ្ម័ន**

ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា ។

តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សំរេច

**មាត្រា ១ :** ត្រូវបានបង្កើត គណៈបញ្ជាការឯកភាពនៅថ្នាក់ ខេត្ត ក្រុង និង ថ្នាក់ស្រុក ខណ្ឌ ក្នុងព្រះរាជាណាចក្រកម្ពុជា ។

### សមាសភាពគណៈបញ្ជាការឯកភាពមាន :

### ក- គណៈបញ្ជាការឯកភាព ខេត្ត ក្រុង :

| | |
|---|---|
| ១- អភិបាលខេត្ត ក្រុង | ជាប្រធាន |
| ២- អភិបាលរងទី ១ | ជាអនុប្រធាន |
| ៣- មេបញ្ជាការតំបន់ប្រតិបត្តិការសឹករង | ជាអនុប្រធាន |
| ៤- ស្នងការនគរបាលខេត្ត ក្រុង | ជាសមាជិកអចិន្ត្រៃយ៍ |
| ៥- ប្រធានមន្ទីរ សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ខេត្ត ក្រុង | ជាសមាជិក |
| ៦- អភិបាលស្រុក ខណ្ឌ | ជាសមាជិក |

### ខ- គណៈបញ្ជាការឯកភាព ស្រុក ខណ្ឌ :

| | |
|---|---|
| ១- អភិបាល ស្រុក ខណ្ឌ | ជាប្រធាន |
| ២- អភិបាលរង | ជាអនុប្រធាន |
| ៣- មេបញ្ជាការផ្នែកប្រតិបត្តិការសឹករង ស្រុក ខណ្ឌ | ជាអនុប្រធាន |
| ៤- អធិការនគរបាល ស្រុក ខណ្ឌ | ជាសមាជិកអចិន្ត្រៃយ៍ |

៥- ប្រធានការិយាល័យ ផែនការ និង ហិរញ្ញវត្ថុ ស្រុក ខណ្ឌ ជាសមាជិក

៦- ប្រធាន ឃុំ សង្កាត់ ជាសមាជិក

**មាត្រា ២ :** គណៈបញ្ជាការឯកភាព ខេត្ត ក្រុង ស្រុក ខណ្ឌ មានភារកិច្ចដូចតទៅ :

១- សំរបសំរួល និង ចាត់ចែងរាល់ការងារដើម្បីឆ្លើយតបសំណូមពរចាំបាច់នៃភារកិច្ច យោធាសន្តិសុខ នៅមូលដ្ឋាន ។

២- តាមដានក្តាប់ជាប់សភាពការណ៍ ឧបាយកលបែបផែនសកម្មភាព របស់ក្រុមខ្មាំង ដែលមានផែនការ ឬសកម្មភាពបំផ្លិចបំផ្លាញមូលដ្ឋាន ។

៣- មានវិធានការបោសសំអាតក្រុមឡោមភូមិសាស្ត្រ តស៊ូទប់ស្កាត់ពួកលបលួចជ្រៀត ចូល ភូមិ ឃុំ បង្កអំពើវិទ្ធង្សនា ធ្វើភេរវកម្ម បង្កអសន្តិសុខ បង្រ្កាបទាន់ពេល សកម្មភាពធក់ប្លន់ កាប់សំលាប់ ចាប់មនុស្សជំរិតយក ប្រាក់ របស់ពួកក្រុមខ្មាំង សំ ដៅការពារអោយបានសុវត្ថិភាពមូលដ្ឋាន ការពារផ្លូវដែក ផ្លូវគមនាគមន៍ជើងគោក ជើងទឹក ការពារសមិទ្ធិផល របស់សង្គមជាតិក្នុងក្របខ័ណ្ឌ ភូមិសាស្ត្រ ទទួលខុសត្រូវ របស់ខ្លួន ។

៤- មានវិធានការកសាង ពង្រឹងមូលដ្ឋានលើគ្រប់ផ្នែក ពិសេសពង្រឹងអ្នករដ្ឋអំណាច ភូមិ ឃុំ ពង្រឹង កំលាំងនគរបាលប៉ុស្តិ៍រដ្ឋបាល និង កងជីវពលនៅមូលដ្ឋាន ។

៥- គួបផ្សំ សកម្មភាពរបស់គណៈកម្មការចំរុះ បង្ការបង្រ្កាបចោរប្លន់ប្រដាប់អាវុធ ដើម្បី បំផុសចលនា ទូលំទូលាយក្នុងប្រជារាស្ត្រ សំដៅពង្រឹងសន្តិសុខ សណ្តាប់ធ្នាប់ សុវត្ថិភាពសង្គមនៅមូលដ្ឋាន ។

**មាត្រា ៣ :** គណៈបញ្ជាការឯកភាព ខេត្ត ក្រុង ស្រុក ខណ្ឌ មានសិទ្ធិដូចតទៅ :

- ចាត់ចែង និង បញ្ជាការកំលាំងក្នុងក្របខ័ណ្ឌភូមិសាស្ត្រដែលខ្លួនទទួលខុសត្រូវក្នុងកិច្ច ការ យោធា សន្តិសុខ ដូចមានចែងក្នុងមាត្រា ២ ។
- សហការរវាង ខេត្ត និង ខេត្ត ស្រុក និង ស្រុក ដែលមានភូមិសាស្ត្រជាប់គ្នា ដើម្បីអនុវត្តផែនការរួម ពេលចាំបាច់ ។

- បំផុសអោយស្ថាប័នផ្សេងៗ ក្នុងខេត្ត ក្រុង ចូលរួមយុទ្ធនាការ ឬ វគ្គសកម្មភាពពេលមានសំណូមពរចាំបាច់ ។
- គណៈបញ្ជាការឯកភាពថ្នាក់ខេត្ត ក្រុង មានសិទ្ធបញ្ជា និង ត្រួតពិនិត្យគណៈបញ្ជាការឯកភាពថ្នាក់ស្រុកខណ្ឌ ។
- ធ្វើរបាយការណ៍ជាប្រចាំពីសកម្មភាពរបស់ខ្លួនមកថ្នាក់លើ ។

**មាត្រា ៤** : សមាជិកគណៈបញ្ជាការគ្រប់រូបចូលរួមធ្វើការងារ តាមការអញ្ជើញ និង ណែនាំរបស់ប្រធាន គណៈបញ្ជាការឯកភាព និង ទទួលខុសត្រូវចំពោះថ្នាក់លើរបស់ខ្លួន ។

**មាត្រា ៥** : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ អភិបាលខេត្ត ក្រុង ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធិភាពខ្ពស់បំផុត ។

**មាត្រា ៦** : អនុក្រឹត្យនេះមានអនុភាព គតិយុត្តិចាប់ពីថ្ងៃឡាយព្រះហស្តលេខា និងចុះហត្ថលេខានេះតទៅ ។

| | |
|---|---|
| នាយករដ្ឋមន្ត្រីទី ១ | តំណាងនាយករដ្ឋមន្ត្រីទី ២ |
| ព្រះហស្តលេខា និងត្រា | ហត្ថលេខា និងត្រា |
| **នរោត្តម រណឫទ្ធិ** | **ស ខេង** |

* * *